ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការចំរុះកិច្ចការព្រំដែន
លេខៈ..៧៤.ស.ស.១.....អ.ជ.ព.ដ

# សេចក្ដីថ្លែងការណ៍

## របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមប្រកាសទាត់ចោលទាំងស្រុងនូវការចុះផ្សាយបំភ្លើសតាមរយៈការ Comment របស់គណនី Facebook ឈ្មោះ Sila Chey ដែលបានបង្កើតចំណុចបង្គោលព្រំដែនក្លែងក្លាយលេខ៧៨ នៅលើប្រព័ន្ធអ៊ីនធឺណែត កាលថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ដែលចំណុចបង្គោលព្រំដែនក្លែងក្លាយនោះ ខុសគ្នាជាង៥គីឡូម៉ែត្រ ពីបង្គោលព្រំដែនលេខ៧៨ផ្លូវការ។

ដើម្បីបញ្ចៀសនូវការយល់ច្រឡំ **គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** មានកិត្តិយសសូមបំភ្លឺជូនសាធារណមតិជាតិ និងអន្តរជាតិឱ្យបានជ្រាបថា ៖

- បង្គោលព្រំដែនលេខ៧៨ផ្លូវការ គឺជាប្រភេទបង្គោលភ្លោះ រួមមានបង្គោលលេខ៧៨(១) បោះនៅត្រើយខាងលិចទន្លេចាម លើទឹកដីកម្ពុជាក្នុងភូមិសាស្ត្រ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងបង្គោលលេខ៧៨(២) បោះនៅត្រើយខាងកើតទន្លេចាមលើទឹកដីវៀតណាមក្នុងភូមិសាស្ត្រ ស្រុកឡុកនីញ ខេត្តប៊ិញភឿក។ ខ្សែព្រំដែននៅតំបន់នេះដើរតាមពាក់កណ្ដាលទន្លេចាម។ បង្គោលព្រំដែនលេខ៧៨ផ្លូវការនេះត្រូវបានបោះតាមផែនទីផ្លូវការដែលប្រទេសទាំងពីរបានអនុម័តទទួលយក។
- ការបង្កើតចំណុចព្រំដែនលេខ៧៨ក្លែងក្លាយនៅលើប្រព័ន្ធអ៊ីនធឺណែត Google Map នេះបានធ្វើឡើងបន្ទាប់ពីក្រុមជនអគតិមួយចំនួន ដែលមាននិន្នាការប្រឆាំងបានវាយប្រហាររាជរដ្ឋាភិបាលថាបានកាត់ដីឱ្យវៀតណាម ក្រោយពេលដែលកម្ពុជា-វៀតណាម បានចុះហត្ថលេខាលើឯកសារព្រំដែនចំនួន២ កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩ កន្លងមក រួមមានសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩ និងពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។
- ការពិត ចំណុចបង្គោលព្រំដែនផ្លូវការលេខ៧៨មិនបានបោះចូលក្នុងទឹកដីប្រទេសកម្ពុជាជាង៥គីឡូម៉ែត្រដូចការ Comment និងរូបភាពបង្ហាញទីតាំងបង្គោលក្លែងក្លាយរបស់គណនី Facebook Sila Chey នោះឡើយ។

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមអំពាវនាវដល់ជនរួមជាតិទាំងក្នុង និងក្រៅប្រទេស សូមកុំជឿលើរាល់ការបង្ហោះបោកប្រាស់របស់ជនអគតិមួយចំនួន ដែលតែងតែបង្កើតព័ត៌មានក្លែងក្លាយក្នុងចេតនាទុច្ចរិត ដើម្បីវាយប្រហារដល់កិច្ចការព្រំដែនរបស់រាជរដ្ឋាភិបាល។

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមបញ្ជាក់ជូនសាធារណមតិជាតិ និងអន្តរជាតិឱ្យបានជ្រាបជាថ្មីថា ក្នុងកិច្ចការខណ្ឌសីមា និងបោះបង្គោលព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះសម្រេចបានលទ្ធផល៨៤% នៃខ្សែព្រំដែនរួម និងកំពុងបន្តធ្វើឱ្យបានចប់ជាស្ថាពរ១០០% ដើម្បីធានាបាននូវបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ។

ថ្ងៃសុក្រ ៤ កើត ខែមិគសិរ ឆ្នាំកុរ ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន**